# របាយការណ៍

## សិក្ខាសាលាតំរង់ទិស និងបណ្តុះបណ្តាលស្តីពី
## ការបង្ការជាវិជ្ជមាននិងការផ្តល់សេវាពន្យាកំណើត
## សំរាប់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាសនិយម និង
## ឱសថប្រឆាំងមេរោគអេដស៍ និងគ្លីនិកសុខភាពគ្រួសារ
## ខេត្តកំពង់ឆ្នាំង

## The orientation workshop and training on Positive Prevention and Birth Spacing for OI/ART and Family Health Clinic Staffs

**Kampong Chhang Province 29-30 August 2011**

**រៀបចំដោយ**

**មជអសក**

**ឧបត្ថម្ភដោយ**

**១,ទីកន្លែងបណ្តុះបណ្តាល** : សាលប្រជុំនៃសណ្ឋាគារ អាស៊ី

**២,កាលបរិច្ឆេទ** : ថ្ងៃទី ២៩-៣០ ខែ សីហា ឆ្នាំ ២០១១

**៣,គោលបំណង** :

- ផ្សព្វផ្សាយពីគោលគំនិតសំខាន់ៗស្តីពីការបង្ការជាវិជ្ជមាន និងការផ្តល់សេវាពន្យាកំណើតនៅតាមសេវាព្យាបាលជំងឺឱកាសនិយមនិងឱសថប្រឆាំងមេរោគអេដស៍និងគ្លីនិកសុខភាពគ្រួសារ ។
- ផ្តល់ចំណេះដឹង និងជំនាញស្តីពីមធ្យោបាយពន្យាកំណើតដល់បុគ្គលិកដែលបំរើការនៅ សេវា OI /ART និង STD ,
- ពិភាក្សា និងរកការឯកភាពគ្នាលើយន្តការនៃការស្នើសុំ និងរបាយការណ៍ស្តីពីការប្រើប្រាស់មធ្យោបាយពន្យាកំណើត និង ការប្រមូលទិន្នន័យសំរាប់តាមដាន ។

**៤,រៀបចំដោយ** : មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ

**៥,ឧបត្ថម្ភដោយ** : PSI

**៦,សកម្មភាព** :

**ថ្ងៃទី ១ ទី ២៩ ខែ សីហា ឆ្នាំ ២០១១**

-មតិស្វាគមន៍ដោយលោកវេជ្ជ **លឹម លៀងងួន** អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង

-ចំណាប់អារម្មណ៏របស់លោក **សុខ សុគន្ធ** តំណាងអង្គការ PSI

-ចំណាប់អារម្មណ៏របស់ លោកវេជ្ជ **មាស វុំឌ្ឍី** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើ ស្បែក និង កាមរោគ (មជអសក)

-មតិសំណេះសំណាល និង ការប្រកាសបើកដោយ លោកសាស្ត្រាចារ្យ **កេត លីសុវិត្ថា** តំណាងមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក ។

-ការណែនាំខ្លួន ដោយលោកវេជ្ជ គីម ប៊ុណ្ណា មន្ត្រី នៃ មជអសក

-ការបង្ហាញពីកម្មវិធី និង គោលបំណងដោយវេជ្ជ សេង វុធី មន្ត្រី នៃមជអសក

-ការបង្ហាញពីបច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍នៅប្រទេសកម្ពុជា ដោយវេជ្ជ ទូច សារុន

-ទស្សនះស្តីពីការបង្ការជាវិជ្ជមានចំពោះមេរោគអេដស៏ ដោយវេជ្ជ សេង វុធី

-ការប្រើប្រាស់ស្រោមអនាម័យ និង ៧ជំហាននៃការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវ បង្ហាញដោយវេជ្ជ សេង វុធី

-ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន បង្ហាញដោយលោកវេជ្ជ ទូច សារុន រួមទាំងការពិភាក្សា ពីយន្តការបញ្ជូនអ្នកជំងឺពីសហគមន៍ មកមន្ទីរពេទ្យ ។

-ការបង្ហាញពីទំរង់របាយការណ៍ យន្តការបញ្ជូនអ្នកជំងឺក្នុងមន្ទីរពេទ្យ និង ពិភាក្សាពីការបំពេញទំរង់របាយការណ៍ ដោយលោក ផាត់ វាសនា មន្ត្រីគ្រប់គ្រងទិន្នន័យនៃ មជអសក និងសំរបសំរួលដោយវេជ្ជ គឹម ប៊ុណ្ណា។

**ថ្ងៃទី ២ ទី ៣០ ខែ សីហា ឆ្នាំ ២០១១**

-គោលការណ៍គ្រឹះ នៃការពន្យាកំណើត និង សិទ្ធិរបស់អ្នកជំងឺក្នុងការទទួលសេវា បង្ហាញដោយលោកស្រី សំ មាលី មន្ត្រីនៃកម្មវិធីគាំពារមាតា និង ទារកខេត្ត កំពង់ឆ្នាំង និង សំរបសំរួលដោយលោក វេជ្ជ ង៉ូវ បូរ៉ា មន្ត្រី មជអសក។

- និយមន័យ នៃ ការពន្យាកំណើត និង ប្រព័ន្ធការពន្យាកំណើតបង្ហាយដោយ លោកស្រី វ៉ាន់ ជតាវីន

-ការប្រើប្រាស់ឱសថពន្យាកំណើតគ្រាប់ដោយលេបរួមមាន: Oral Contraceptive(COC and Emergency Pill, Oral contraceptive POP និង ការប្រើប្រាសឱសថពន្យាកំណើតដោយចាក់ បង្ហាញដោយលោកស្រី សំ មាលី សំរបសំរួលដោយលោកវេជ្ជ សេង វុធី ។

-ការបំពេញទំរង់របាយការណ៍ពន្យាកំណើត និងទំរង់ផ្សេងៗ ទាក់ទងនឹងការឱសថពន្យាកំណើត បង្ហាញដោយ លោកស្រី សំ មាលី មន្ត្រីនៃកម្មវិធីគាំពារមាតា និង ទារកខេត្ត កំពង់ឆ្នាំង និង សំរបសំរួលដោយលោក វេជ្ជ សេង វុធី មន្ត្រី មជអសក។

## ៧,ចំណុចល្អជាវិជ្ជមាន:

- មានការប្តេជ្ញាចិត្តខ្ពស់លើការអនុវត្តន៏សកម្មភាពផ្តល់សេវាពន្យាកំណើតនៅសេវា OI/ART ។
- មណ្ឌលសុខភាពនៅជិតមន្ទីរពេទ្យខេត្តកំពង់ឆ្នាំងដែលបង្កលក្ខណៈងាយស្រួលដល់ការផ្តល់ឱសថ និង មធ្យោបាយពន្យាកំណើតដល់ក្រុម OI/ART and STD team
- មានការគាំទ្រចូលរួមយ៉ាងសកម្ម និង សហការណ៍ពីអង្គការក្នុងការបញ្ជូនស្ត្រីមានផ្ទៃពោះសង្ស័យ ពីសហគមន៍ ដោយក្រុមថែទាំអ្នកជំងឺអេដស៏តាមផ្ទះដូចជា: PC, WVC , CPR, CWPD
- មានការសហការណ៏រវាងផ្នែកគាំពារមាតា និងទារកខេត្ត និង កម្មវិធីអេដស៏ខេត្តក្នុងការដាក់ដំណើរការសកម្មភាពថ្មីនេះ ។

## ៨,បញ្ហានានា:

- ធនធានមនុស្សច្រើនមកពីកន្លែងផ្សេងៗជាហេតុដំណើរការមិនទាន់រលូន លើការងារពន្យាកំណើត។
- ការឧបត្ថម្ភប្រាក់លើកទឹកចិត្ត យឺត និង សំភារៈការិយាល័យខ្វះខាត់សំរាប់ដំណើរការ ។
- ការប្រើប្រាស់ស្រោមអនាម័យកន្លងមកមិនគ្រប់គ្រាន់ទេចំពោះអ្នកផ្ទុកមេរោគអេដស៏ សំណូមពរសុំ ១០ ស្រោមទើបប្រើគ្រាន់ ។
- ការដាក់អោយដំណើរការសកម្មភាពនេះ ហាក់ដូចជាបន្ថែមការងារថ្មីដល់ក្រុមគាត់ទៀត ។

**៩.ចំណុចត្រូវតាមដាន និងសកម្មភាពបន្ត:**

- MCH ខេត្ត សហការណ៍ជាមួយ PASP ត្រូវជួយសំរបសំរួលផ្តល់ឱសថពន្យាកំណើតដូចជា Pill Depo ដោយជួយវាយតំលៃពីតំរូវការជាក់ស្តែង ការប្រើប្រាស់ និង តាមដានផ្តល់បច្ចេកទេស ដល់បុគ្គលិក OI/ART បន្ថែមទៀត តាមរយៈការចុះអភិបាលរួមពីកម្មវិធីអេដស៍ខេត្តដោយ ប្រើប្រាស់ថវិកាមូនិធិសកល ។
- ឱសថពន្យាកំណើតត្រូវបានស្នើសុំ ពីមណ្ឌលសុខភាពកំពង់ឆ្នាំងដែលនៅជិតដោយប្រើប្រាស់ បណ្តោះអាសន្ន មួយរយៈពេលសិន ។
- បុគ្គលិក OI/ART សំណូមពរសុំបញ្ចូលឱសថពន្យាកំណើតទៅក្នុងកញ្ចប់ CMS ដែលផ្តល់ដោយផ្ទាល់ដល់ក្រុម OI/ART នៃមន្ទីរពេទ្យខេត្ត ។

**១០.សេចក្តីសន្និដ្ឋាន:**

វគ្គសិក្ខាសាលាតំរង់ទិស និង បណ្តុះបណ្តាលការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យាកំណើតសំរាប់បុគ្គលិកសេវាព្យាបាលជំងឺឱកាសនិយម និង ឱសថប្រឆាំងមេរោគអេដស៍បានដំណើរប្រកបទៅដោយជោគជ័យ ក្រោមការប្រកាសបិទដោយលោកសាស្ត្រាចារ្យ **កេត លីសុដ្ឋា** អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក និង លោកវេជ្ជ **មាស វុឌ្ឍី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍សើស្បែក និង កាមរោគ ក្រោមការប្តេជ្ញាចិត្តរបស់ក្រុម OI/ART ថាដំណើរការអនុវត្តសកម្មភាពបង្ការជាវិជ្ជមាននាដើមខែ កញ្ញា ឆ្នាំ ២០១១នេះ ។

ភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១

អ្នកធ្វើរបាយការណ៍

លោកវេជ្ជ សេង វុធី

បានឃើញ និង ឯកភាព

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ

នឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជ មាន_ឈីវុន